# ‘ការអនុវត្តអព្យាក្រឹតកាបូនជាមួយកូន’សូមរួមគ្នាការពារផែនដី

តើអ្នកដឹងទេថាដោយសារសីតុណ្ហភាពមធ្យមរបស់ផែនដីកំពុងកើនឡើងបាតុភូតអាកាសធាតុមិនប្រក្រតីកំពុងកើតមាននៅតំបន់ជាច្រើនជុំវិញពិភពលោក? ប្រទេសរបស់យើងក៏ដូចគ្នាដោយសាររដូវផ្ការីកនិងរដូវស្លឹកឈើជ្រុះកាន់តែខ្លីធ្វើអោយយើងមិនអាចទទួលបានរដូវទាំងបួនយ៉ាងពេញលេញដូចមុនទៀតទេ។ លើសពីនេះឧស្ម័នផ្ទះកញ្ចក់ដែលបញ្ចេញពីកន្លែងផ្សេងៗលើផែនដីកំពុងបង្កឲ្យមានការប្រែប្រួលអាកាសធាតុយ៉ាងខ្លាំងដែលនាំអោយប្រទេសជាច្រើនទទួលរងផលប៉ះពាល់ដូចជាការបំពុលខ្យល់, ភាពរាំងស្ងួត, ទឹកជំនន់។ល។ ម្យ៉ាងទៀតធូលីល្អិតនិងខ្យល់ពុលក៏កំពុងគំរាមកំហែងដល់សុខភាពកូនៗរបស់យើងដោយបណ្តាលឲ្យមានជំងឺផ្សេងៗដូចជាអាឡែស៊ីស្បែកនិងជំងឺហឺត។ ដូច្នេះយើងសូមណែនាំអំពីវិធីអនុវត្តអព្យាក្រឹតកាបូនដែលអាចធ្វើជាមួយកូនៗបានដូចខាងក្រោម។ សូមចូលរួមការពារបរិស្ថានដើម្បីអនាគតរបស់កូនៗយើងទាំងអស់គ្នា



## Q. តើអព្យាក្រឹតភាពកាបូនជាអ្វី?



អព្យាក្រឹតកាបូនមានន័យថាការបង្កើតវិធានការសម្រាប់ស្រូបយកកាបូនឌីអុកស៊ីតឲ្យស្មើនឹងបរិមាណដែលបានបញ្ចេញដើម្បីធ្វើឲ្យបរិមាណការបញ្ចេញជាក់ស្តែងក្លាយជា“0”។ និយាយម្យ៉ាងទៀតគឺធ្វើឲ្យបរិមាណការបញ្ចេញកាបូនឌីអុកស៊ីតជាក់ស្តែងក្លាយជា“0”។



## Q. មូលហេតុដែលយើងត្រូវអនុវត្តអព្យាក្រឹតកាបូន



មូលហេតុធំបំផុតដែលយើងត្រូវអនុវត្តអព្យាក្រឹតកាបូនគឺដោយសារតែ “ការប្រែប្រួលអាកាសធាតុ”។ ការកើនឡើងនៃកាបូនឌីអុកស៊ីតដែលបញ្ចេញពីទូទឹកកក,រថយន្តនិងរោងចក្រកំពុងបង្កអោយមានបាតុភូតផែនដីឡើងកម្តៅ។ ដោយសារតែបញ្ហានេះក៏កំពុងកើតមានបញ្ហាសង្គមនិងសេដ្ឋកិច្ចជាច្រើនផងដែរដូចជាភ្លៀងធ្លាក់ខ្លាំងភ្លាមៗភាពរាំងស្ងួតការកើនឡើងនៃជំងឺថ្មីៗនិងការបាក់ស្រុតតំបន់ឆ្នេរសមុទ្រ។



## Q. ចូរយើងអនុវត្តរឿងនេះជាមួយគ្នា



សូមបែងចែកសំរាមសម្រាប់ចោលអោយបានត្រឹមត្រូវក្នុងជីវិតប្រចាំថ្ងៃ។



ស្រោចទឹកឲ្យស្មៅ និងផ្កាដែលនៅជិត



ដើរនៅចម្ងាយជិតៗ



ដាំដើមឈើជាមួយម៉ាក់និងប៉ា



ដើររើសសំរាម (រើសសំរាម)

